ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Apr-2015, 15:16
CMS/CFO: Sann Rada

# នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស |
| **ដាក់ទៅ** | : | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់** | : | ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

## ចំណាត់ថ្នាក់ឯកសារ

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សម្ងាត់**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ ក.ស.ច.ស:** សម្ងាត់/Confidential

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំឲ្យទុក ជាមោឃៈនូវដីកាបង្គាប់ឲ្យនាំខ្លួន មាស មុត ដែលបានចេញនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤**

---

<u>អ្នកដាក់ឯកសារ:</u>
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

<u>អ្នកទទួលឯកសារ:</u>
**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

<u>ចម្លងជូន:</u>
**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

<u>ចម្លងជូន:</u>
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**ជនត្រូវចោទ**
**មាស មុត**
លោក អាង ឧត្តម
លោក Michael KARNAVAS

## I. សេចក្តីផ្តើម

1. មាស មុត បានស្នើ[1] ("សំណើ") សុំឱ្យសហចៅក្រមស៊ើបអង្កេត ទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួនគាត់ ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (សចអ) នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ ("ដីកាបង្គាប់ឱ្យនាំខ្លួន") ។ មាស មុត អះអាងថា សចសអ មិនមានអំណាចជាបុគ្គល អាចចេញដីកាបង្គាប់ឱ្យនាំខ្លួននេះទេ ហើយដែលអាចជំនួសបាន គឺពេលនេះអសារឥតបាន ការដែល មាស មុត ត្រូវបានជូនដំណឹងពីការចោទប្រកាន់នានាប្រឆាំងនឹងរូបគាត់។ សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") សូមឆ្លើយតបថា អំណះអំណាងរបស់ មាស មុត គឺពុំមានអង្គសេចក្តីទេ ហើយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបដិសេធសំណើនោះចោល។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ សចសស បានចុះបញ្ជីនូវការខ្វែងយោបល់គ្នាពាក់ព័ន្ធនឹងសំណុំរឿង ០០៣[2]។

3. នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ សចអ បានចេញដីកាកោះ មាស មុត ឱ្យមកកាន់ អវតក ដើម្បីបង្ហាញខ្លួនលើកដំបូង នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤[3]។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ អ្នកស៊ើបអង្កេតម្នាក់នៃការិយាល័យសហចៅក្រមស៊ើបអង្កេត បានប្រគល់ដីកាកោះឱ្យទៅ មាស មុត[4]។

4. តាមព័ត៌មាន និងការជឿជាក់ថា នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ មេធាវីការពារក្តី មាស មុត ត្រូវបានកោះហៅឱ្យចូលរួមការបង្ហាញខ្លួនលើកដំបូងរបស់គាត់[5]។

---

[1] **D130** សំណើរបស់ មាស មុត សុំឱ្យទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤, ១០ មីនា ២០១៥ (ចាប់ពីនេះតទៅហៅថា "សំណើ" (ជូនដំណឹងជាភាសាខ្មែរ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥)។

[2] **D128** ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*, ៣ មីនា ២០១៥។

[3] **A66** ដីកាកោះលោក មាស មុត ដើម្បីបង្ហាញខ្លួនលើកដំបូង, ៨ ធ្នូ ២០១៤។

[4] **A66** ដីកាកោះលោក មាស មុត ដើម្បីបង្ហាញខ្លួនលើកដំបូង, ៨ ធ្នូ ២០១៤។

[5] **D128** ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*, ៣ មីនា ២០១៥, ត្រង់កថាខណ្ឌ ១៥ (ដោយបានលើកឡើងពីឯកសារលេខ A67 ដីកាកោះអញ្ជើញមេធាវី, ២៨ វិច្ឆិកា ២០១៤)។ សហព្រះរាជអាជ្ញាមិនអាចមើកមើលឯកសារលើកឡើងនេះបានទេ។

5. តាមព័ត៌មាន និងការជឿជាក់ថា មាស មុត បានជម្រាបព័ត៌មានទៅ សចអ តាមរយៈលិខិតមួយ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៤ ថាគាត់មិនបានទទួលស្គាល់ពីសុពលភាពនៃដីកាកោះ ដែលមិនបានចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតជាតិនោះទេ ហើយនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ មេធាវីការពារក្តី មាស មុត បានជម្រាបព័ត៌មានទៅសហចៅក្រមស៊ើបអង្កេតថា កូនក្តីរបស់គាត់មិនមានបំណងធ្វើតាមដីកាកោះនោះទេ[6]។

6. តាមព័ត៌មាន និងការជឿជាក់ថា សចអ បានឆ្លើយតបទៅកាន់ មាស មុត វិញនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤ ដោយបានរំឭកថា "អង្គបុរេជំនុំជម្រះ បានបញ្ជាក់រួចហើយអំពីសុពលភាពនៃដីកាកោះហៅឱ្យបង្ហាញខ្លួនលើកដំបូងដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ដរាបណា នីតិវិធីដោះស្រាយករណីខ្វែងយោបល់គ្នាដូចមានចែងនៅក្នុងវិធាន៧២ នៃវិធានផ្ទៃក្នុង ត្រូវបានអនុវត្ត ហើយរយៈពេល ៣០ថ្ងៃ សម្រាប់បញ្ជូនករណីខ្វែងយោបល់គ្នាទៅដោះស្រាយ នៅចំពោះមុខអង្គបុរេជំនុំជម្រះបានកន្លងផុត"[7]។

7. នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ សចអ បានកំណត់អំពីការបង្ហាញខ្លួន មាស មុត លើកដំបូង[8]។ ក្រុមមេធាវីការពារក្តី មាស មុត បានចូលរួម ប៉ុន្តែ មាស មុត មិនបានចូលរួមទេ[9]។

8. នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ សចអ បានចេញដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត ដោយបានកត់សម្គាល់អំពីការខកខានរបស់គាត់ក្នុងការបង្ហាញខ្លួនលើកដំបូង[10]។ សចអ បានបង្គាប់ឱ្យនគរបាល

---

[6] **C1** ដីកាបង្គាប់ឱ្យនាំខ្លួន, ១១ ធ្នូ ២០១៤, ទំព័រ ២ (ដោយបានលើកឡើងពីឯកសារលេខ A67/1.1 សេចក្តីជូនដំណឹងអំពីការមិនទទួលស្គាល់ដីកាកោះ, ២ ធ្នូ ២០១៤។ ឯកសារលេខ A67/1 ទាក់ទងនឹងសេចក្តីសម្រេចចិត្តរបស់ មាស មុត មិនទទួលស្គាល់ដីកាកោះ, ៣ ធ្នូ ២០១៤)។ សហព្រះរាជអាជ្ញាមិនអាចមើកមើលឯកសារលើកឡើងទាំងនេះបានទេ។

[7] **C1** ដីកាបង្គាប់ឱ្យនាំខ្លួន, ១១ ធ្នូ ២០១៤, ទំព័រ ២ (ដោយបានលើកឡើងពីឯកសារលេខ A67/1/1 ការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងទាក់ទងនឹងសេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ [sic] ដីកាកោះ, ចុះថ្ងៃទី៣ និង៤ ខែធ្នូ ឆ្នាំ២០១៤)។ សហព្រះរាជអាជ្ញាមិនអាចមើកមើលឯកសារលើកឡើងនេះបានទេ។

[8] **D122** កំណត់ហេតុនៃការចូលខ្លួនដំបូង, ១១ ធ្នូ ២០១៤។

[9] **D122** កំណត់ហេតុនៃការចូលខ្លួនដំបូង, ១១ ធ្នូ ២០១៤, ត្រង់ទំព័រ ២។

[10] **C1** ដីកាបង្គាប់ឱ្យនាំខ្លួន, ១១ ធ្នូ ២០១៤។

យុត្តិធម៌ចាត់វិធានការលើដីកាបង្គាប់ឲ្យនាំខ្លួនឲ្យមានប្រសិទ្ធិភាព ដើម្បីនាំ មាស មុត ឲ្យមកបង្ហាញខ្លួនលើកដំបូង។

9. នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ សចអ បានផ្ញើលិខិតមួយច្បាប់ ជូនទៅ ឯ.ឧ. ឯម សំអាន ជារដ្ឋលេខាធិការនៅក្រសួងមហាផ្ទៃ និងជាប្រធាននៃគណៈកម្មាធិការសន្តិសុខ អវតក ដោយបានកត់សម្គាល់អំពីដីកាបង្គាប់ឲ្យនាំខ្លួនដែល មាស មុត មិនបានគោរពតាម[11]។ សចអ បានជម្រាប ឯ.ឧ. ឯម សំអាន ថាដោយមកពីការខកខានមិនបានគោរពតាមដីកាបង្គាប់ឲ្យនាំខ្លួន សចស មានបំណងដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* បើ មាស មុត មិនចូលខ្លួនមក អវតក ឬ មិនគោរពតាមដីកាបង្គាប់ឲ្យនាំខ្លួន នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ទេ។

10. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ សចអ បានដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ដោយចោទប្រកាន់ពីឧក្រិដ្ឋកម្មនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[12]។ តាមអ្វីដែល សហព្រះរាជអាជ្ញាបានដឹងគឺ ដីកាបង្គាប់ឲ្យនាំខ្លួន មិនទាន់ត្រូវបានគោរពតាមនៅឡើយទេ។

## III. **ចម្លើយតប**

## **ក. ដីកាបង្គាប់ឲ្យនាំខ្លួន គឺមានសុពលភាព**

11. មាស មុត អះអាងថា ដីកាបង្គាប់ឲ្យនាំខ្លួនគឺមិនមានសុពលភាពទេ ពីព្រោះវាមិនត្រូវបានចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប[13]។ គាត់បានរក្សាគំនិតថា ការចេញដីកាបង្គាប់ឲ្យនាំខ្លួនដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ជា "កិច្ចដែលមិនមានចែងក្នុងយុត្តិសាស្ត្រ ច្បាប់ ឬវិធាននៅ អវតក"[14]។ ផ្ទុយទៅវិញ ករណីយុត្តិសាស្ត្រ ច្បាប់ និងវិធានផ្ទៃក្នុងរបស់ អវតក បានគិតទុកជាមុន និងបានគាំទ្រដល់សកម្មភាពស៊ើបសួរនានាដែលបានធ្វើឡើងដោយ សហចៅក្រមស៊ើបអង្កេតតែម្នាក់ ដរាបណាសកម្មភាពស៊ើបសួរទាំងនោះត្រូវបានធ្វើឡើងដោយស្របតាមនីតិវិធីពាក់ព័ន្ធ។

[11] **D127** សំបុត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជូន ឯកឧត្តម ឯម សំអាន, ៣០ មករា ២០១៥។

[12] **D128** ដីកាសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*, ៣ មីនា ២០១៥។

[13] **D130** សំណើ, ត្រង់កថាខណ្ឌ ២៥-៣០។

[14] **D130** សំណើ, ត្រង់កថាខណ្ឌ ៣៦។

12. វិធាន៧២ នៃវិធានផ្ទៃក្នុង បានលើកឡើងយ៉ាងច្បាស់លាស់អំពីការដោះស្រាយការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត[15] ហើយសូម្បីតែមានការខ្វែងយោបល់គ្នារវាងចៅក្រមក៏ដោយ ក៏អនុញ្ញាតឲ្យមាន "កិច្ច ឬសេចក្ដីសម្រេច ដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះ ត្រូវតែអនុវត្ត" លើកលែងតែនៅក្នុងកាលៈទេសៈមួយចំនួនដែលមិនអាចអនុវត្តបានចំពោះការចេញដីកាបង្គាប់ឲ្យនាំខ្លួន[16]។ លើសពីនេះ បើសហចៅក្រមស៊ើបអង្កេតមិនធ្វើការជ្រើសរើសយកការដាក់បណ្ដឹងស្ដីពីការខ្វែងយោបល់គ្នានោះទៅឲ្យអង្គបុរេជំនុំជម្រះ (អបជ)ទេ នោះកិច្ច ឬសេចក្ដីសម្រេចនោះ ត្រូវអនុវត្តតាម។ ដូចអ្វីដែល អបជ ធ្លាប់បានសម្រេចហើយថា "សហចៅក្រមស៊ើបអង្កេតមិនមានកាតព្វកិច្ចក្នុងការជូនដំណឹងដល់អង្គបុរេជំនុំជម្រះទេ នៅពេលខ្លួនមិនព្រមព្រៀងគ្នាលើបញ្ហាណាមួយនៅចំពោះមុខ ហើយក្នុងករណីនេះ សេចក្ដីសម្រេចនោះគឺថា "ការស៊ើបអង្កេតត្រូវតែបន្ត"..."[17]។ ដូច្នេះ វិធានផ្ទៃក្នុងបានគាំទ្រច្បាស់ណាស់អំពីការចេញដីកាបង្គាប់ឲ្យនាំខ្លួនដោយ សចអ តែម្នាក់។

13. ក្នុងការគាំទ្រអំណះអំណាងរបស់ខ្លួន មាស មុត បានដកស្រង់ដាក់ជូនទៅអង្គជំនុំជម្រះនេះនូវប្រយោគទីមួយនៃមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង[18] ដែលគាត់គិតថាជា "ផ្នែកពាក់ព័ន្ធ"[19]។ គាត់បានបង្កប់ន័យនៅក្នុងប្រយោគមួយតាមការយល់ឃើញរបស់គាត់ថា "សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត" បញ្ជាក់ថាកិច្ចការទាំងអស់ត្រូវតែចាត់ការឡើងរួមគ្នាដោយសហចៅក្រមស៊ើបអង្កេតទាំងពីរ[20]។ ជាបញ្ហាដែលត្រូវពឹងពាក់ទៅលើឯកសារ ការជាប់ជំពាក់ទាក់ទងបែបដូច្នេះគឺពិតជាខុសយ៉ាងច្បាស់ក្រឡែត។ កិច្ចសហការរវាងចៅក្រមនានាមិនមានចែងនៅក្នុងកិច្ចព្រមព្រៀងទេ។ លើសពីនេះ មាត្រា៥(៤) បានចែងបន្តទៀត នៅបន្ទាប់ពីប្រយោគខ្លីដែល មាស មុត បានដកស្រង់ ដោយបានទទួលស្គាល់យ៉ាងជាក់ច្បាស់ថា ការខ្វែងយោបល់គ្នាអាចនឹងកើតឡើងបាន ហើយនៅក្នុងករណីបែបដូច្នេះ សេចក្ដី

[15] វិធាន ៧២ នៃវិធានផ្ទៃក្នុង។

[16] វិធាន ៧២(៣) នៃវិធានផ្ទៃក្នុង។

[17] **D427/1/30** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១, ត្រង់កថាខណ្ឌ ២៧៥។

[18] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ៦ មិថុនា ២០០៣។

[19] **D130** សំណើ, ត្រង់កថាខណ្ឌ ២៥។

[20] **D130** សំណើ, ត្រង់កថាខណ្ឌ ២៥, ៣០។

សម្រេចនោះគឺថាការស៊ើបអង្កេតត្រូវតែបន្ត ដោយបានចែងថា៖ "នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថាតើត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃ ឲ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា៧"។ ដូច្នេះ មាត្រា៥(៤) នៃកិច្ចព្រមព្រៀង កាលណាពិនិត្យមើលទាំងមូលទៅ ហើយកុំពិនិត្យមើលចោះៗ នោះគឺមានលក្ខណៈគាំទ្រយ៉ាងច្បាស់ក្រឡែតដល់វិធានការនានាដែលបានចាត់ឡើង ដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ក្នុងការស៊ើបសួរ រួមទាំងការចេញដីកាបង្គាប់ឲ្យនាំខ្លួន។

មាស មុត គឺដូចជាធ្វើឲ្យគេយល់ខុសដោយចោះៗដែរ នៅពេលដែលបានធ្វើការដកស្រង់ពីក្នុងច្បាប់ស្ដីពីការបង្កើត អវតក[21]។ គាត់បានបញ្ជាក់ថា "ផ្នែកពាក់ព័ន្ធ" នៃមាត្រា២៣ថ្មី ចែងថា "រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់..." ដោយអះអាងជាថ្មីម្ដងទៀតថា ការណ៍នេះតម្រូវឲ្យសហចៅក្រមស៊ើបអង្កេត ត្រូវតែចាត់ការរួមគ្នាលើគ្រប់កិច្ចការទាំងអស់[22]។ ជាថ្មីម្ដងទៀត ជាបញ្ហាដែលត្រូវពឹងពាក់ទៅលើឯកសារ ក្នុងការដែលមានការបកស្រាយខុស។ ចៅក្រមទាំងពីរមាន "ការទទួលខុសត្រូវ" ក្នុងការស៊ើបអង្កេត គឺមិនបានធ្វើឲ្យចៅក្រមទាំងពីរគិតដូចគ្នាថាត្រូវមានការព្រមព្រៀងទៅលើសកម្មភាពនីមួយៗនៅក្នុងកិច្ចស៊ើបសួរទេ។ ហើយជាថ្មីម្ដងទៀត ផ្នែកទាំងឡាយនៅក្នុងមាត្រានេះដែល មាស មុត បានរំលងចោល គឺមានលក្ខណៈច្បាស់លាស់ណាស់ដែលថា ការខ្វែងយោបល់ទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ ព្រមទាំងសកម្មភាពនានាធ្វើឡើងដោយចៅក្រមម្នាក់ ក្នុងចំណោមពួកគាត់ពីរនាក់ គឺត្រូវបានគិតបម្រុងទុកយ៉ាងជាក់ច្បាស់នៅក្នុងច្បាប់ស្ដីពីការបង្កើត អវតក។ មាត្រា២៣ថ្មី បន្ទាប់ពីប្រយោគខ្លីដែល មាស មុត បានដកស្រង់ បានចែងបន្តទៀតដើម្បីលើកឡើងពីនីតិវិធីដែលអាចអនុវត្តបាន៖ "ក្នុងករណីដែលមានភាពមិនយល់ស្របគ្នារវាងសហចៅក្រមស៊ើបអង្កេត" ហើយបានបន្តថាការមិនមានការព្រមព្រៀងគឺ "ការស៊ើបអង្កេតត្រូវធ្វើបន្ត..."។ ដូច្នេះ មាត្រា២៣ថ្មី ក៏មានលក្ខណៈគាំទ្រយ៉ាងច្បាស់លាស់ដល់វិធានការនានាក្នុងការស៊ើបអង្កេត ដែលចាត់ឡើងដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ រួមទាំង ការចេញដីកាបង្គាប់ឲ្យនាំខ្លួនផងដែរ។

[21] ច្បាប់ស្ដីពី ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិតេយ្យ ដោយបញ្ចូលវិសោធនកម្មនានា ដែលបានប្រកាសឲ្យប្រើ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

[22] **D130** សំណើ, ត្រង់កថាខណ្ឌ ២៥។

14. ដូចគ្នាទៅនឹងវិធានផ្ទៃក្នុងដែរ កិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើត អវតក ក៏ដូចជាករណីយុត្តិសាស្ត្ររបស់ អវតក គឺសុទ្ធតែបានអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតតែម្នាក់ធ្វើសកម្មភាពរបស់ខ្លួន នៅក្នុងដំណើរការនៃការស៊ើបសួរ រួមទាំងការចេញដីកាបង្គាប់ឱ្យនាំខ្លួនផង។ មាស មុត បានទទួលស្គាល់ថា នៅក្នុងសំណុំរឿង០០៤ អបជ ធ្លាប់បានសម្រេចថា ដីកាកោះអាចចេញដោយចៅក្រមតែម្នាក់។ គាត់បានអះអាងថា "សហចៅក្រមស៊ើបអង្កេត Harmon បានពង្រីកសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលត្រូវបានកំហិតក្នុងសំណុំរឿង០០៤ មកដល់ដីកាបង្គាប់ឱ្យនាំខ្លួនជាឯកតោភាគី"[23]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតតែម្នាក់ មានអំណាចចេញដីកាបង្គាប់ឱ្យនាំខ្លួន ហើយសេចក្ដីសម្រេចរបស់ អបជ ដែលបានយោង គឺបានទទួលស្គាល់គោលការណ៍ យ៉ាងច្បាស់ក្រឡែត។

15. នៅក្នុងសេចក្ដីសម្រេចនោះ អបជ បានរកឃើញថា ការអះអាងដែលថាចៅក្រមស៊ើបអង្កេតតែម្នាក់"មិនមានអំណាចចេញដីកាកោះតែម្នាក់ឯងនោះ"*យោងតាមភ័ស្តុតាងបឋម* គឺគ្មានអង្គសេចក្ដីទេ[24]។ ដរាបណាឱ្យតែនីតិវិធីស្ដីពីការខ្វែងយោបល់គ្នាជាធរមានណាមួយ ត្រូវបានគោរពតាម អបជ បានសម្រេចថា "តាមរយៈកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ច្បាប់ និងវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក គឺជាការច្បាស់ណាស់ សហចៅក្រមស៊ើបអង្កេតអាចចេញដីកាកោះហៅអ្នកណាម្នាក់ក៏បាន"[25]។ សម្រាប់ការសម្រេចនេះ អបជ បានលើកយោងមាត្រា៥(៤)នៃកិច្ចព្រមព្រៀង និងមាត្រា២៣ថ្មីនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ជាបទប្បញ្ញត្តិតែមួយគត់ដែល មាស មុត អះអាងថាគាំទ្រចំពោះការតវ៉ារបស់គាត់ ដែលថាចៅក្រមស៊ើបអង្កេតតែម្នាក់មិនអាចចាត់សកម្មភាពតែម្នាក់ឯងបានទេ ព្រមទាំងវិធាន៧២ផង។ អាស្រ័យហេតុនេះ ករណីយុត្តិសាស្ត្ររបស់ អបជ គាំទ្រចំពោះលទ្ធភាពរបស់ចៅក្រមស៊ើបអង្កេតតែម្នាក់ ដើម្បីអនុវត្តមុខងាររបស់ការិយាល័យនេះ រួមទាំងដីកាបង្គាប់ឱ្យនាំខ្លួនផង ស្របនឹងវិធាន៧២។

[23] **D130** សំណើ, ត្រង់កថាខណ្ឌ ២៦។

[24] **D117/1.2** សេចក្ដីសម្រេច (កោសលុប) លើសំណើបន្ទាន់ (កោសលុប), ១៥ សីហា ២០១៤, ត្រង់កថាខណ្ឌ១៤។

[25] **D117/1.2** សេចក្ដីសម្រេច (កោសលុប) លើសំណើបន្ទាន់ (កោសលុប), ១៥ សីហា ២០១៤, ត្រង់កថាខណ្ឌ២៥។

16. មាស មុត មិនបានផ្តល់ការគាំទ្រណាមួយចំពោះការតវ៉ារបស់គាត់ទេដែលថា "សិទ្ធិជាមូលដ្ឋាននឹងទទួលរងនូវហានិភ័យ បើមានវិធានការណាមួយ - ដូចជាការចេញដីកាបង្គាប់ឲ្យនាំខ្លួននេះជាដើម -ដែលបានដាក់ដោយការិយាល័យសហចៅក្រមស៊ើតអង្កេតដែលអាចកម្រិតដល់សិទ្ធិនេះ ត្រូវតែមានការព្រមព្រៀងគ្នាដោយសហចៅក្រមស៊ើបអង្កេតទាំងពីរ"[26]។ ដោយគ្មានការគាំទ្រអ្វីបន្តិចសោះដូច្នេះ និងដោយសារសកម្មភាពរបស់ចៅក្រមតែម្នាក់ដូច្នេះ មានការគិតគូទុកជាមុននៅក្នុងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង នោះការអះអាងដូចនេះគួរតែត្រូវបានបដិសេធចោល។

17. មាស មុត ក៏តវ៉ាផងដែរថា "សហចៅក្រមស៊ើបអង្កេត Harmon មិនអាចពឹងផ្អែកទៅលើនីតិវិធីដំណោះស្រាយមាននៅក្នុងវិធាន៧២ ដើម្បីចេញដីកាបង្គាប់ឲ្យនាំខ្លួន ដោយគ្មានហត្ថលេខារបស់សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង"[27]ឡើយ។ ផ្ទុយទៅវិញ ដូចបានជំរាបជូនរួចហើយថា វិធាន ៧២ គឺអនុញ្ញាតឲ្យធ្វើបាន។ លើសពីនេះ អំណះអំណាងរបស់ មាស មុត ចំពោះគោលជំហររបស់គាត់ គឺមិនអាចបញ្ចុះបញ្ចូលបានទេ។ គាត់ពឹងផ្អែកទាំងស្រុងទាំងលើតែមតិមួយរបស់ចៅក្រមជាតិមួយរូបនៃអង្គបុរេជំនុំជម្រះតែប៉ុណ្ណោះ (ដែលជាហេតុមិនឲ្យទទួលបានសម្លេងភាគច្រើនដូចបានតម្រូវ[28]) ដែលនិយាយថា "បើគ្មានសហព្រះរាជអាជ្ញាណាម្នាក់បានផ្ទេរសិទ្ធិអំណាចរបស់គាត់ទៅឲ្យសហព្រះរាជអាជ្ញាម្នាក់ផ្សេងទៀតទេនោះ គឺសហព្រះរាជអាជ្ញាម្នាក់ទៀតក៏មិនអាច បំពេញកិច្ចតែម្នាក់ឯងបាននោះដែរ"[29]។

18. ប៉ុន្តែ មតិរបស់ចៅក្រមជាតិដែល មាស មុត ពឹងផ្អែកលើនោះ គឺផ្ទុយគ្នានឹងសេចក្តីសម្រេចរបស់អបជ ដែលទទួលបានសម្លេងភាគច្រើនចាំបាច់ និងដែលបានទទួលស្គាល់ថា "សហព្រះរាជអាជ្ញាឬសហចៅក្រមស៊ើបអង្កេតមួយរូប អាចបំពេញកិច្ចតែម្នាក់ឯងបាន បើសិនការខ្វែងយោបល់គ្នាត្រូវបានចុះបញ្ជីរួចរាល់នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ឬការិយាល័យសហចៅក្រមស៊ើបអង្កេតតាមករណីសមស្រប និងរយៈពេលនាំយកការខ្វែងយោបល់គ្នា មកចំពោះមុខអង្គបុរេជំនុំជម្រះបាន

---

[26] **D130** សំណើ, ត្រង់កថាខណ្ឌ២៧។

[27] **D130** សំណើ, ត្រង់កថាខណ្ឌ២៩។

[28] កិច្ចព្រមព្រៀង មាត្រា៧(៤)។

[29] **D130** សំណើ, ត្រង់កថាខណ្ឌ២៩, ដកស្រង់ឯកសារ D20/4/4 (មតិរបស់ចៅក្រម ប្រាក់ គឹមសាន, ន័យ ថុល និង ហ្វ៊ូត រិទ្ធី) កថាខណ្ឌ៤។

កន្លងផុត”[30]។ អបជ បានបញ្ជាក់បន្ថែមទៀតពីសិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេតតែម្នាក់ ដូចករណីនៃការចេញដីកាបង្គាប់ឲ្យនាំខ្លួន គេមិនចាំបាច់រង់ចាំរហូតដល់រយៈពេលដោះស្រាយបានកន្លងផុតទៅ មុនពេលចាប់ផ្ដើមបំពេញកិច្ចយ៉ាងដូច្នេះថា៖ “កិច្ចព្រមព្រៀង ច្បាប់អ.វ.ត.ក និងវិធានផ្ទៃក្នុង ចែងថា សហចៅក្រមស៊ើបអង្កេតម្នាក់អាចបំពេញកិច្ចតែម្នាក់ឯងបានយ៉ាងត្រឹមត្រូវ ប្រសិនបើលក្ខខណ្ឌតម្រូវនៃនីតិវិធីខ្វែងយោបល់គ្នាត្រូវបានអនុវត្ត។ ចំពោះករណីបច្ចុប្បន្នវិញគេមិនចាំបាច់ធានាឲ្យប្រាកដថា រយៈពេលដោះស្រាយ៣០ថ្ងៃបានកន្លងផុត មុនពេលសហចៅក្រមស៊ើបអង្កេតអន្តរជាតិអាចចេញ[សេចក្ដីសម្រេចរបស់គាត់]នោះទេ ឲ្យតែការខ្វែងយោបល់នោះមិនពាក់ព័ន្ធនឹងការកម្រិតដូចមានចែងក្នុងកថាខណ្ឌ(ក) ដល់(គ) នៃវិធាន៧២(៣)”[31]។

19. អំណះអំណាងចុងក្រោយរបស់ មាស មុត ទាក់ទងនឹងការទាមទាររបស់គាត់ដែលថា ដីកាបង្គាប់ឲ្យនាំខ្លួន មិនបានចេញត្រឹមត្រូវ គឺមានន័យថាមាត្រា៥(៤) នៃកិច្ចព្រមព្រៀង និងមាត្រា២៣ថ្មី នៃច្បាប់ អ.វ.ត.ក “មិនអាចស្រូបយកទាំងមូលដោយវិធាន៧៤ឡើយ សម្រាប់គោលបំណងស្វ័យបំរើតាមរយៈការបកស្រាយវិធាននេះថាអនុញ្ញាតឲ្យមានការអនុវត្តចំពោះការបំពេញកិច្ច ឬសេចក្ដីសម្រេច*ទាំងអស់* ដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត”ឡើយ ដោយសារតែ “លទ្ធផលបែបនេះនឹងរំលោភលើស្មារតី និងគោលបំណងរបស់កិច្ចព្រមព្រៀងផង និងច្បាប់បង្កើត អ.វ.ត.ក”[32] ផង។ វិធាន៧៤ ពាក់ព័ន្ធនឹងទម្រង់ករណ៍សម្រាប់បណ្ដឹងឧទ្ធរណ៍នៅមុនដំណាក់កាលជំនុំជម្រះ ហើយ មាស មុត មិនបានបំភ្លឺថាហេតុអ្វីគាត់ជឿថា សចសអ កំពុងតែស្រូបយកដើម្បីបំរើឲ្យខ្លួនឯង នូវមាត្រាដូចបានលើកយោងនេះ ទៅក្នុងវិធាន៧៤ ឬពីរបៀបណាមួយដែលនឹងជួយដល់អំណះអំណាងរបស់គាត់ឡើយ។ ប៉ុន្តែ ដោយមិនចាំបាច់គិត ដូចបានបង្ហាញជូនរួចហើយថា មាត្រាទាំងនោះគឺច្បាស់ណាស់អនុញ្ញាតឲ្យចៅក្រមស៊ើបអង្កេតតែម្នាក់ អាចបំពេញកិច្ចបាន ដូច្នេះការបកស្រាយណាមួយដូច្នេះមិនរំលោភលើស្មារតី និងគោលបំណងនៃកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ឡើយ។

---

[30] **D117/1.2** សេចក្ដីសម្រេច (កោសលុប) លើសំណើបន្ទាន់ (កោសលុប), ១៥ សីហា ២០១៤, ត្រង់កថាខណ្ឌ១៤ និងកំណត់សំគាល់ជើងទំព័រ២៣។

[31] **D208/1/1/2** សាលដីកា [កោសលុប] លើបណ្ដឹងឧទ្ធរណ៍របស់ ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣, ២២ មករា ២០១៥, ត្រង់កថាខណ្ឌ១១ (សេចក្ដីយោងខាងក្នុងត្រូវបានលប់)។ វិធាន៧២(៣)(គ) អនុវត្តចំពោះដីកាបង្គាប់ឲ្យចាប់ខ្លួន ប៉ុន្តែដីកានេះ គឺខុសគ្នាពីដីកាបង្គាប់ឲ្យនាំខ្លួន។ *ប្រៀបធៀប* វិធាន៤២ *ជាមួយ* វិធាន៤៤។

[32] **D130** សំណើ, ត្រង់កថាខណ្ឌ៣០ (សង្កត់ន័យដើម)។

## ខ. ដីកាបង្គាប់ឱ្យនាំខ្លួនមិនគួរទុកជាមោឃៈឡើយ

20. មាស មុត តវ៉ាថា បើទោះជាដីកាបង្គាប់ឱ្យនាំខ្លួនបានចេញដោយត្រឹមត្រូវក៏ដោយ ក៏ពេលនេះដីកានេះគួរទុកជាមោឃៈ ដោយសារគេមានសំអាងថា វាលែងចាំបាច់ទៀតហើយ អាស្រ័យដោយគោលបំណងនៃដីកាបង្គាប់ឱ្យនាំខ្លួននេះ បានសម្រេចហើយ[33]។ គាត់តវ៉ាថា ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានចេញដើម្បីនាំខ្លួន មាស មុត មកចំពោះមុខ កសចស សម្រាប់គោលបំណងនៃការបង្ហាញខ្លួនលើកដំបូង និងថា ដោយសារការជូនដំណឹងអំពីបទចោទបានចេញរួចហើយ ដូច្នេះការចូលបង្ហាញលើកដំបូងមិនចាំបាច់ទេ។

21. អំណះអំណាងរបស់ មាស មុត ដែលធ្វើឡើងក្រោមការសន្មតបែបបំភាន់ថា មូលហេតុតែមួយគត់សម្រាប់តម្រូវឱ្យជនជាប់ចោទណាម្នាក់បង្ហាញខ្លួននៅចំពោះមុខ កសចស ចំពោះការចូលបង្ហាញខ្លួនលើកដំបូង គឺដើម្បីផ្ទេរព័ត៌មានដែលមាននៅក្នុងការជូនដំណឹងអំពីបទចោទប្រកាន់[34]។ ការបង្ហាញខ្លួនរបស់ មាស មុត នៅចំពោះមុខ កសចស សម្រាប់ការចូលបង្ហាញខ្លួនជាលើកដំបូង នឹងបំរើឱ្យគោលបំណងជាច្រើន រួមទាំងការអនុញ្ញាតឱ្យមានការចោទ *មកលើរូបគាត់ដោយផ្ទាល់* និងសម្រាប់ សចសអ គឺដើម្បីបំពេញចិត្តរបស់គាត់ផ្ទាល់ផងដោយហេតុថា មាស មុត បានយល់ពីបទចោទប្រឆាំងរូបគាត់ និងអំពីសិទ្ធិរបស់គាត់ផង[35]។ ដូច្នេះ ដីកាបង្គាប់ឱ្យនាំខ្លួន នៅតែបន្តបំរើឱ្យគោលបំណងមួយដដែល ហើយប្រហែលជាលែងចាំបាច់តែនៅពេលណា មាស មុត បានចូលមកបង្ហាញខ្លួនដោយស្ម័គ្រចិត្តនៅចំពោះមុខ កសចស ដើម្បីទទួលការចោទប្រកាន់ប្រឆាំង *បុគ្គលគាត់ផ្ទាល់* តែប៉ុណ្ណោះ។

---

[33] **D130** សំណើ, ត្រង់កថាខណ្ឌ៣១-៣២។

[34] **D128** សេចក្ដីសម្រេចចោទប្រកាន់ មាស មុត *ដោយកំបាំងមុខ*, ៣ មីនា ២០១៥។

[35] គោលបំណងនេះត្រូវបានឆ្លុះបញ្ចាំងក្នុងវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់តុលាការអន្តរជាតិ និងតុលាការមានលក្ខណៈជាអន្តរជាតិដទៃទៀត។ *សូមមើល ឧទាហរណ៍* តុលាការពិសេសសម្រាប់ប្រទេសលីបង់, វិធានស្ដីពីនីតិវិធី និងភស្តុតាង, ៣ មេសា ២០១៤, វិធាន 98(A)(i)-(ii)។ តុលាការអន្តរជាតិសម្រាប់ការវិនិច្ឆ័យទោសជនទាំងឡាយដែលទទួលខុសត្រូវចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តិនៅលើទឹកដីនៃអតីតយូហ្គោស្លាវីតាំងពីឆ្នាំ១៩៩១,វិធានស្ដីពីនីតិវិធី និងភស្តុតាង, ២២ ឧសភា ២០១៣, វិធាន 62(A)(i)-(ii)។ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន, វិធានស្ដីពីនីតិវិធី និងភស្តុតាង, ២៨ ឧសភា ២០១០, វិធាន 61(i)-(ii)។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា, វិធានស្ដីពីនីតិវិធី និងភស្តុតាង, ១០ មេសា ២០១៣, វិធាន 62(A)(i)-(ii)។

22. មាស មុត ក៏តវ៉ាដែរថា ដីកាបង្គាប់ឱ្យនាំខ្លួន មិនគួរទុកឱ្យនៅចំហរ "ដោយគ្មានមូលហេតុផ្សេងទៀត ជាជាងឃុំឃាំង មាស មុត ជាបណ្តោះអាសន្នឡើយ"[36]។ គាត់តវ៉ាថា "ការឃុំឃាំងនៅដំណាក់កាលនេះ ទោះជាបណ្តោះអាសន្នបែបណាក្តីគឺជាការធ្វើឱ្យបាត់បង់សេរីភាពរបស់ លោក មាស មុត តាមទំនើងចិត្តដែលមិនកម្រិតឱ្យបានតឹងរ៉ឹងទៅនឹងភាពចាំបាច់នៃដំណើរការនីតិវិធី"[37]នោះ ជាថ្មីម្តងទៀតគឺបានពឹងផ្អែកទៅលើការទាមទាររបស់គាត់ថា ដីកាបង្គាប់ឱ្យនាំខ្លួន គឺសម្រាប់គោលបំណងនៃការបង្ហាញខ្លួនលើកដំបូង ហើយការបង្ហាញខ្លួនលើកដំបូងនេះ "បានធ្វើរួចហើយ ដោយអានុភាព"[38]។ សហព្រះរាជអាជ្ញានៅប្រកាន់ជំហរថា ការចូលបង្ហាញខ្លួនលើកដំបូងមិនបានបានធ្វើទេ បើគិតពីចំណុចសំខាន់នៃពាក្យថា *ដោយផ្ទាល់ខ្លួន* អាស្រ័យហេតុនេះ អំណះអំណាងថា ដីកាបង្គាប់ឱ្យនាំខ្លួន ច្រើនហួសតម្រូវការ ឬថាបាន និងកំពុងរក្សាទុក "សម្រាប់ហេតុផលផ្សេង ជាជាងឃុំឃាំង មាស មុត ជាបណ្តោះអាសន្ន"[39] គឺគ្មានមូលដ្ឋានទេ។

23. លើសពីនេះ ការឃុំឃាំងបណ្តោះអាសន្នដែលចាំបាច់ធ្វើឱ្យមានប្រសិទ្ធភាពដល់ដីកាកោះរបស់តុលាការដែលបានចេញដោយត្រឹមត្រូវ មិនមែនជាការធ្វើតាមទំនើងចិត្តទេ[40]។ ដោយមិនបាច់គិត សហព្រះរាជអាជ្ញាកត់សំគាល់ឃើញថា សចសអ បានអនុញ្ញាតឱ្យឃុំឃាំងជាបណ្តោះអាសន្ននៅក្រោមដីកាបង្គាប់ឱ្យនាំខ្លួនតែនៅក្នុងស្ថានភាពដែល "មាស មុត អាស្រ័យដោយកាលៈទេសៈ មិនអាចនាំខ្លួន

---

[36] **D130** សំណើ, ត្រង់កថាខណ្ឌ៣៥។

[37] **D130** សំណើ, ត្រង់កថាខណ្ឌ៣៤។

[38] **D130** សំណើ, ត្រង់កថាខណ្ឌ៣៤។

[39] **D130** សំណើ, ត្រង់កថាខណ្ឌ៣៥។

[40] *សូមមើល* ទាហរណ៍ អនុសញ្ញាស្តីពីសិទ្ធិមនុស្សសហគមអឺរ៉ុប, មាត្រា 5 § 1(b) ("មនុស្សគ្រប់រូបមានសិទ្ធិសេរីភាព និងសន្តិសុខបុគ្គល។ គ្មាននរណាម្នាក់ត្រូវបានគេដកហូតសិទ្ធិសេរីភាពចំពោះករណីដូចខាងក្រោមនេះ និងស្របតាមនីតិវិធីដែលបានចែងដោយច្បាប់:... ការចាប់ខ្លួន ឬការឃុំឃាំងដោយខុសច្បាប់នៃជនណាម្នាក់ដោយសារការមិនបានអនុវត្តតាមសេចសម្រេចស្របច្បាប់របស់តុលាការ ឬដើម្បីបំពេញកាតព្វកិច្ចផ្លូវច្បាប់ណាមួយដូចមានចែងក្នុងច្បាប់")។ *Benham ទល់នឹង United Kingdom*, សាលក្រម, លេខ 19380/92, ១០ មិថុនា ១៩៩៦, កថាខណ្ឌ៤២ ("ជាគោលការណ៍ ចិរវេលានៃការឃុំឃាំងនឹងត្រូវគិតថាស្របច្បាប់ វៀរលែងតែការឃុំឃាំងនោះត្រូវបានធ្វើឡើងអនុលោមតាមដីកាសម្រេចរបស់តុលាការ។ ការរកឃើញនាពេលបន្តបន្ទាប់ថា តុលាការមានកំហុសតាមច្បាប់របស់ប្រទេស ក្នុងការធ្វើដីកាសម្រេចនោះ មិនមែនមានន័យថាមានផលប៉ះពាល់ធាក់ថយទៅលើសុពលភាពនៃរយៈពេលឃុំឃាំងអន្តរាគមន៍ឡើយ")។ *Göthlin ទល់នឹងប្រទេសស៊ុយអែត*, សាលក្រម, លេខ 8307/11, ១៦ តុលា ២០១៤, កថាខណ្ឌ៥៥-៦៨ (រកឃើញថាគ្មានការរំលោភមាត្រា៥ នៃអនុសញ្ញា ECHR ទេ ពីព្រោះការឃុំឃាំងទទួលបានប្រសិទ្ធិភាព ដោយសារម្ចាស់ពាក្យសុំខកខានមិនបានអនុវត្តតាមដីកាសម្រេចរបស់តុលាការ)។

មកចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិជាបន្ទាន់បាន"[41] សម្រាប់គោលបំណងនៃការចូលបង្ហាញខ្លួនលើកដំបូង។ ដោយសារ មាស មុត មិនទាន់ត្រូវបានឃុំខ្លួន ហើយអាចមិនត្រូវបានឃុំខ្លួន ជាការឆាប់ពេកសម្រាប់គាត់តវ៉ាអំពីការឃុំឃាំងដែលឈរលើទឡ្ហីករណ៍តាមទំនើងចិត្ត ឬទឡ្ហីករណ៍ផ្សេងពីនេះ។

## VI. **ដំណោះស្រាយដែលស្នើឡើង**

24. អាស្រ័យមូលហេតុដូចបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើសហចៅក្រមស៊ើបអង្កេត **ច្រានចោល** សំណើសុំនេះ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៥ | **លោក Nicholas KOUMJIAN** សហព្រះរាជអាជ្ញា | ភ្នំពេញ | |

[41] **C1** ដីកាបង្គាប់ឲ្យនាំខ្លួន, ១០ ធ្នូ ២០១៤, ត្រង់ទំព័រ៣។